ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

-សាលក្រមព្រហ្មទណ្ឌលេខ: ៤៩ "គ"
ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០
-សំណុំរឿងព្រហ្មទណ្ឌលេខ: ៥៧២
ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨
-សំណុំរឿងស៊ើបសួរលេខ: ១០៥៥
ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨
-សំណុំរឿងជំនុំជម្រះលេខ: ៨៦
ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០

# តា ម នា ម ប្រ ជា រា ស្ត្រ ខ្មែ រ

## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង២:៣០ រសៀល នៅសាលសវនាការលេខ: ១B ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខ: ៥៧២ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] ឡេ ហែលឡូខូ ([redacted] LE HELLOCO) ភេទប្រុស អាយុ៤៦ឆ្នាំ ជនជាតិបារាំង កើតនៅទីក្រុងLOUDEAC ទីលំនៅបច្ចុប្បន្ននៅRUA DO SACRAMENTO A LAPA NO14 1200-794 LISOA PORTUGAL មុខរបរប្រធានអគ្គនាយកក្រុមហ៊ុនVikoria Invest (អតីតEEM)កាន់សាសនាគ្រិស្ត កម្រិតវប្បធម៌ អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ប្រពន្ធឈ្មោះ [redacted] អេមីលី [redacted] EMILIE) មានកូនចំនួន០២នាក់ ឪពុកឈ្មោះ [redacted] ហែលឡូខូ ហ្គាយ(LE HELLOCO GUY) "រស់" ម្តាយឈ្មោះ [redacted] ឃេនទីឡេ(LOYER DANIELE) "រស់" ទោសពីមុនគ្មាន។(គេចខ្លួន)

ត្រូវជាប់ចោទពីបទ: **កំហែងយក និងធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចតុលាការ** ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៦៣,មាត្រា៣៦៤,មាត្រា៥២៣ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហ្វ្រង់ស្វ័រ កុងធៀរ (François Gontier) ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិបារាំង ទីលំនៅបច្ចុប្បន្ននៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរលេខ: ១២៩៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ១៣១១ អ.យ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៧៨៦១ ពស.ព្រស ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប។

**អង្គហេតុកើតមានដូចតទៅ**

កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] **កុងជេរ** ([redacted] Gontier) ជាប្រធានក្រុមហ៊ុនប្រឹក្សាភិបាល និងជាអ្នកគ្រប់គ្រងក្រុមហ៊ុន(VAK) ដែលវិនិយោគលើសេវាកម្មសណ្ឋាគារ Victoria Angkor Resort & Spa តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ៣៧២ "ឈ" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់តុលាការកំពូលបានសម្រេចបញ្ឈប់លោក [redacted] **ទ្រិក អាល់ប៊ឺតប្រុន** ([redacted] Albert Pronk) ពីតំណែង និងភារកិច្ចក្នុងសណ្ឋាគារព្រោះតែកំហុសធ្ងន់ធ្ងរ។ក្រោយមកឈ្មោះ [redacted] **កុងជេរ** [redacted] Gontier) បានជ្រើសរើសឈ្មោះ [redacted] Guillien ឱ្យកាន់តំណែងជំនួសឈ្មោះ [redacted] **អាល់ប៊ឺតប្រុន** ([redacted] Albert Pronk) ជាអ្នកគ្រប់គ្រងសណ្ឋាគារ Victoria Angkor Resort & Spa ក្នុងឋានៈជាអគ្គនាយក(GM)។ស្រាប់តែថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] **ឡេ ហែលឡូខូ** [redacted] LE HELLOCO) ភេទប្រុស អាយុ៤៦ឆ្នាំ សញ្ជាតិបារាំង និងគូកន បានប្រើប្រាស់ទឹកប្រាក់ចំនួន២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក ដើម្បីបង្ខិតបង្ខំឱ្យឈ្មោះ Raphael Guillien ដែលតែងតាំងដោយឈ្មោះ [redacted] **កុងជេរ** [redacted] Gontier) គ្រប់គ្រងស្របច្បាប់លើក្រុមហ៊ុន(VAK) ធ្វើជាអ្នកចាត់ការទូទៅនៅសណ្ឋាគារ Victoria Angkor Resort & Spa ដើម្បីបោះបង់ចោលមុខតំណែងរបស់ខ្លួនក្នុងគោលបំណងយកឈ្មោះ [redacted] **អាល់ប៊ឺតប្រុន** ([redacted] Albert Pronk) មកគ្រប់គ្រងសណ្ឋាគារវិញ។

**នាពេលសវនាការ**

-តាមអំណានពាក្យបណ្តឹង ថា: កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ និង៤៥នាទីរសៀល ឈ្មោះ [redacted] Helloco ដែលអះអាងថាខ្លួនជាប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកក្រុមហ៊ុនViktoria Invest ដែលចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសបារាំងបាននាំគ្នីគ្នារួមមាន: ឈ្មោះ [redacted] Albert Pronk ដែលក្រុមហ៊ុនបានបញ្ឈប់ពីការងាររួចហើយ អមដោយលោកមេធាវីចំនួន៣នាក់បម្រើការងារនៅការិយាល័យមេធាវីសិទ្ធិស៊ុគ្គី ដឹកនាំដោយលោកមេធាវី [redacted],មន្ត្រីអាវុធហត្ថម្នាក់ និងអ្នកសារព័ត៌មានម្នាក់ទៀតចូលមកត្រួតត្រាកាន់កាប់ទីតាំងសណ្ឋាគារទាំងស្រុង ដោយមិនមានការអនុញ្ញាតពីរូបខ្លួន

ហើយបានបង្ខិតបង្ខំឱ្យឈ្មោះ [redacted] Guillien ភេទប្រុស ដែលខ្លួនតែងតែឱ្យធ្វើជាអគ្គនាយកសណ្ឋាគារបណ្ដោះអាសន្នចេញពីសណ្ឋាគារនៅវេលាម៉ោង១៩ល្ងាច នាថ្ងៃដដែលជាថ្នូរនឹងទឹកប្រាក់ចំនួន២០០០០(ពីរម៉ឺន)ដុល្លារអាមេរិក ដើម្បីបោះបង់តួនាទីរបស់ខ្លួនជាអគ្គនាយកសណ្ឋាគារ។ លើសពីនេះទៅទៀតឈ្មោះ [redacted] Le Helloco បានប្រើប្រាស់ឯកសារមួយចំនួនដែលមិនស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជាធ្វើជាមូលដ្ឋាន ដើម្បីបិទលែងឱ្យដំណើរការចរាចរណ៍សាច់ប្រាក់របស់ក្រុមហ៊ុននៅគណនីធនាគារចំនួនគឺ: នៅធនាគារANZ Royal Bank សាខាខេត្តសៀមរាប គណនីលេខ 119651-4 និងនៅធនាគារ Mekong Bank សាខាខេត្តសៀមរាប គណនីលេខ 113-01-000909-9 ធ្វើឱ្យរាំងស្ទះដល់ការបើកផ្ដល់ប្រាក់ឈ្នួលដល់បុគ្គលិក និយោជិតសណ្ឋាគារ ព្រមទាំងប្រតិបត្តិការសេវាកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុនយ៉ាងធ្ងន់ធ្ងរ។ ប៉ុន្តែគណនីធនាគារទាំងនោះក្រោយមកត្រូវបានបើកឱ្យដំណើរការឡើងវិញជាប្រក្រតី បន្ទាប់ពីមានពាក្យបណ្ដឹងសុំដីកាសម្រេចរក្សាការពាររបស់ខ្លួន ដោយយចាត់ចែងរក្សាការពារលេខ: ៤៧ ព.ស/១៨ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាប ។ ខ្លួនសំណូមពរ: ផ្ដន្ទាទោសជនល្មើសតាមច្បាប់,កុំឱ្យជនល្មើសធ្វើដំណើរចេញចូលក្រៅប្រទេសក្រៅដែនដីព្រះរាជាណាចក្រកម្ពុជា និងសុំទាមទារសងសំណងការខូចខាតផលប្រយោជន៍របស់ក្រុមហ៊ុន និងជំងឺចិត្ត ព្រមទាំងសេវាផ្លូវច្បាប់ផ្សេងៗស្មើនឹងទឹកប្រាក់ចំនួន១០០០.០០០.០០០(មួយពាន់លាន)រៀល។

-អំណានចម្លើយរបស់មេធាវី [redacted] ថា: ឈ្មោះ [redacted] Gontier បានប្ដឹងឈ្មោះ [redacted]e Helloco និងគូកនពីបទអំពើកំហែងយក និងបទអោយបាត់ជំនឿលើសេចក្ដីសម្រេចរបស់តុលាការ ប្រព្រឹត្តនៅទីតាំងសណ្ឋាគារ Victoria Ankor Resort Spa មានទីតាំងស្ថិតនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។ឈ្មោះ [redacted] Albert Pronk សញ្ជាតិ ហូឡង់ ត្រូវបានក្រុមហ៊ុន(VAK) ជួលមកឱ្យមើលការងារខុសត្រូវក្នុងនាមជាអគ្គនាយកសណ្ឋាការ Victoria Ankor Resort Spa តែដោយសារមានកំហុសធ្ងន់ធ្ងរក៏ត្រូវបានឈ្មោះ [redacted] Gonthier ជាអ្នកគ្រប់គ្រងក្រុមហ៊ុនតាមអំណាចសាលដីកាតុលាការកំពូល បញ្ឈប់ពីការងារវិញ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ បច្ចុប្បន្នឈ្មោះ [redacted] Albert Pronk នេះក៏ត្រូវបានអយ្យការអមសាលាដំបូងខេត្តសៀមរាប ចោទប្រកាន់ក្លាយជាជនត្រូវចោទរួចហើយដែរពីបទសុំផ្ដល់ឯកសារដោយទុច្ចរិត តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៣២២ អយ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨។ស្របពេលនោះកាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] Le Helloco សញ្ជាតិ បារាំង និងគូកនបាននាំឈ្មោះ [redacted] Albert Pronk និងក្រុមមេធាវីបម្រើការងារនៅការិយាល័យ[illegible]ចូលមកត្រួតត្រាកាន់កាប់ទីតាំងសណ្ឋាគារយ៉ាងកំរោលទាំងស្រុង ហើយឈ្មោះ [redacted] Le Helloco

ក៏បានបណ្តេញឈ្មោះ [redacted] Guillien ភេទប្រុស ដែលឈ្មោះ [redacted] Gontier ជួលមកឱ្យមើលការងារខុសត្រូវសណ្ឋាគារក្នុងនាមជាអគ្គនាយក ចេញពីសណ្ឋាគារទាំងតក់ក្រហល់ជាថ្នូរ និងទឹកប្រាក់ចំនួន២០០០០(ពីរម៉ឺន)ដុល្លារអាមេរិក ដើម្បីបោះបង់តួនាទីរបស់ខ្លួនជាអគ្គនាយកសណ្ឋាគារ។ លើសពីនេះទៅទៀតឈ្មោះ [redacted] Le Helloco បានប្រើប្រាស់ឯកសារមួយចំនួនដែលមិនស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជាធ្វើជាមូលដ្ឋាន ដើម្បីបិទលែងឱ្យដំណើរការចរាចរណ៍សាច់ប្រាក់របស់ក្រុមហ៊ុននៅគណនីធនាគារចំនួនពីរគឺៈ នៅធនាគារANZ Royal Bank សាខាខេត្តសៀមរាប គណនីលេខ 119651-4 និងនៅធនាគារ Mekong Bank សាខាខេត្តសៀមរាប គណនីលេខ 113-01-000909-9 ធ្វើឱ្យរាំងស្ទះដល់ការបើកផ្តល់ប្រាក់ឈ្នួលដល់បុគ្គលិក និយោជិតសណ្ឋាគារ ព្រមទាំងប្រតិបត្តិការសេវាកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុនយ៉ាងធ្ងន់ធ្ងរ។នៅពេលនេះលោក Francois Gontier សំណូមពរៈផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសុំទាមទារសងសំណងការខូចខាតផលប្រយោជន៍របស់ក្រុមហ៊ុន និងជំងឺចិត្ត ព្រមទាំងសេវាផ្លូវច្បាប់ផ្សេងៗស្មើនឹងទឹកប្រាក់ចំនួន១000.000.000 (មួយពាន់លាន)រៀល។

-អំណានចម្លើយរបស់មេធាវី [redacted] ថាៈ ក្នុងនាមខ្លួនជាមេធាវីតំណាង និងការពារសិទ្ធិឱ្យឈ្មោះ [redacted] Gonthies ជាដើមបណ្តឹងរដ្ឋប្បវេណី សូមរក្សាចម្លើយរបស់សហភាគា គឺលោកមេធាវី [redacted] នៅចំពោះមុខតំណាងអយ្យការអមសាលាសាលាដំបូងខេត្តសៀមរាប និងរក្សាពាក្យសុំផ្តល់ឯកសារភស្តុតាងជូនពិនិត្យបន្ថែម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ និងចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ របស់លោកមេធាវី [redacted] និងរក្សាខ្លឹមសារនៃពាក្យបណ្តឹង ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] Gontiers នៅដដែលទាំងស្រុងដោយឥតមានកែប្រែអ្វីឡើយ។ខ្លួនសំណូមពរមេត្តាជួយសម្រេចផ្តល់យុត្តិធម៌តាមនីតិវិធីនៃច្បាប់ឱ្យកូនក្តីខ្លួនឈ្មោះ [redacted] Gontier ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាពាណិជ្ជករបរទេស។

-អំណានដីកាចាត់ចែងរក្សាការពារលេខៈ ៤៧ ព.ស/១៨ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាប សម្រេច ថាៈ បង្គាប់ឱ្យធនាគារ ANZ Royal Bank សាខាខេត្តសៀមរាប បើកដំណើរការជាធម្មតាឡើងវិញ នូវគណនីលេខ 119651-4 របស់ក្រុមហ៊ុន Victoria Angkor Company Limites (VAK) ដែលបានបិទកន្លងមក និងបង្គាប់ឱ្យធនាគារ Mekong Bank សាខាខេត្តសៀមរាប បើកដំណើរការជាធម្មតាឡើងវិញ នូវគណនីលេខ 113-01-000909-9 របស់ក្រុមហ៊ុន Victoria Angkor Company Limites (VAK) ដែលបានបិទកន្លងមក។

-អំណានសាលក្រមលេខ: ២៩ (ខ១) ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ថា: ផ្តន្ទាទោសឈ្មោះ [redacted] Albert Pronk ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិហូឡង់ ដាក់ពន្ធនាគារកំណត់១៨(ដប់ប្រាំបី)ខែ និងពិន័យជាប្រាក់ចំនួន៣.០០០.០០០(បីលាន)រៀល ពីបទ: **ស៊ុំផ្តល់ឯកសារដោយទុច្ចរិត** ប្រព្រឹត្តនៅខេត្តសៀមរាប កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៦៣ នៃក្រមព្រហ្មទណ្ឌ និងអោយឈ្មោះ [redacted] Albert Pronk សងសំណងការខូចខាតចំនួន៣០.០០០.០០០ (សាមសិបលាន)រៀល និងជម្ងឺចិត្តចំនួន២០.០០០.០០០(ម្ភៃលាន)រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] កុងដេរ [redacted] Gontier) ច្រានចោលការទាមទារលើសពីនេះ។

-អំណានសាលដីកាលេខ: ៣៧២ ឈ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់តុលាការកំពូល ថា: ច្រានចោលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលើកទី២ លេខ ២៤២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០១៣ របស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយឈ្មោះ [redacted] Adre។តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤១ ក្រVI "ញ" ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ទុកជាបានការចំណុចទី៤ នៃសេចក្តីសម្រេច "បង្គាប់ឲ្យក្រុមហ៊ុនវីតូរីយ៉ា ខមភីនី លីមីតធីត ដែលមានឈ្មោះភាគហ៊ុនរួមគ្នាសងបំណុលរួមចំនួន ៨៨៤.៣៩៦(ប៉ែតសិបប្រាំបីម៉ឺន បួនពាន់ពីររយកៅសិបប្រាំមួយ)ដុល្លារអាមេរិក ទៅម្ចាស់បំណុលតាមសមាមាត្រ យោងតាមលក្ខន្តិកៈក្រុមហ៊ុន: លោក [redacted] Gotier ៧៥% ស្មើនឹង ៦៦៣.២១៩(ហុកសិបប្រាំមួយម៉ឺន បីពាន់ ពីររយដប់ប្រាំបួន)ដុល្លារអាមេរិក,លោក [redacted] Gauthier ២៣% ស្មើនឹង ២០៣.៣៨៧,១៦ (ម្ភៃម៉ឺន បីពាន់ បីរយ ប៉ែត្រសិបប្រាំពីរក្បៀសដប់ប្រាំមួយ)ដុល្លារអាមេរិក ,លោក [redacted] Adre ២% ស្មើនឹង ១៧.៦៨៥,៨៤ (មួយម៉ឺនប្រាំពីរពាន់ ប្រាំមួយរយ ប៉ែត្រសិបប្រាំក្បៀសប៉ែត្រសិបបួន)ដុល្លារអាមេរិក។ត្រូវបដិសេធចោលចំណុចទី៦ នៃសេចក្តីសម្រេច "បង្គាប់ឲ្យលោក [redacted] Adre ដែលមានភាគហ៊ុន២% សងជំងឺចិត្តចំនួន ៥០០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក ឲ្យទៅលោក [redacted] Gontier ត្រូវកែប្រែមកជា "បង្គាប់ឲ្យលោក Pierre Adre ដែលមានភាគហ៊ុន ២% សងជំងឺចិត្តចំនួន២០០០០(ពីរម៉ឺន)ដុល្លារអាមេរិក ឲ្យទៅលោក [redacted] Gontier ជាតំណាងក្រុមហ៊ុន ELECTRICITE ET EAUE MADAGASCAR COMPANY LIMITED (EEM) និងជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនសណ្ឋាគារ Vitoria Angkor មានទីស្នាក់ការ ស្ថិតនៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

-អំណានសាលដីកាលេខ: ៤១ ក្រVI"ញ" ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ថា: ទទួលជំនុំជម្រះសំណុំរឿងរដ្ឋប្បវេណីលេខ: ០៦៥ ចុះថ្ងៃទី២៩ ខែកុម្ភៈ

ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ តាមអំណាចសាលដីការដ្ឋវេណីឈ្មោះ ៣១០ "ច" ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១២ របស់តុលាការកំពូល។ច្រានពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០០៩ និងបណ្តឹងសុំកែតម្រូវ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១១ របស់ដើមចោទ ចោលជាអសារបង់។ទទួលពាក្យតប ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១១ របស់ចុងចម្លើយទុកជាត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់។បង្គាប់ឲ្យក្រុមហ៊ុន វីតូរីយ៉ាអង្គរ ខមភីនី លីមីតធីត ដែលមានម្ចាស់ភាគហ៊ុនរួមគ្នាសងបំណុលរួមចំនួន ៨៨៤២៩២ (ប្រាំបីសែន ប្រាំបីម៉ឺន បួនពាន់ ពីររយកៅសិបពីរ)ដុល្លារអាមេរិក ទៅម្ចាស់បំណុលតាមសមាមាត្រ យោងលក្ខន្តិកៈរបស់ក្រុមហ៊ុន លោក [redacted] Gontier ៧៥% ស្មើនឹង ៦៦៣២១៩ ដុល្លារអាមេរិក,លោក Bernnard Gaithier ២៣% ស្មើនឹង ២០៣៣៧៨,១៦ ដុល្លារអាមេរិក,លោក [redacted] Adre ២% ស្មើនឹង ១៧៦៨៥,៨៤ ដុល្លារអាមេរិក។បញ្ឈប់ឲ្យដាក់ក្រុមហ៊ុន វីតូរីយ៉ាអង្គរ ខមភីនី លីមីតធីត របស់ម្ចាស់ភាគហ៊ុន ២៣% ដែលមានឈ្មោះ [redacted] Gaithier និង ២% ដែលមានម្ចាស់ភាគហ៊ុនឈ្មោះ [redacted] Adre ចាប់ពីពេលនេះតទៅ។ប្រគល់ក្រុមហ៊ុន វីតូរីយ៉ាអង្គរ ខមភីនី លីមីតធីត ឲ្យទៅលោក [redacted] Gonthier គ្រប់គ្រង។បង្គាប់ឲ្យលោក [redacted] Adre ដែលមានភាគហ៊ុន ២% សងជំងឺចិត្តចំនួន ៥០០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ឲ្យទៅលោក Francois Gonthier នៅពេលសាលដីកានេះចូលស្ថាពរ។

-អំណានលិខិត ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ របស់ឈ្មោះ ហ្វ្រង់ស្វ័រកុងជេរ ថាៈ ប្រធានក្រុមប្រឹក្សាភិបាល និងជាអ្នកគ្រប់គ្រងក្រុមហ៊ុន Victoria Angkor Company Limited (VAK) ដែលវិនិយោគលើសេវាកម្មសណ្ឋាគារ Victoria Angkor Resort Spa តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ៣៧២ (ឈ) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់តុលាការកំពូល។សូមប្រកាសជូនដំណឹងលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីការបញ្ឈប់លោក [redacted] Albert Pronk សញ្ជាតិបារាំង ពីការងារដោយសារមានកំហុសធ្ងន់ធ្ងរ។

-អំណានរបាយការណ៍សន្តិសុខ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ថាៈ ខាងសណ្ឋាគារបានបញ្ឈប់លោកប៉ាទ្រីក តែគាត់បានត្រឡប់មកវិញវេលាម៉ោង០១.០៥នាទី ក្រោយមកមានការអន្តរាគមន៍ពីខាងសន្តិសុខអោយគាត់ចេញពីសណ្ឋាគារវិញវេលាម៉ោង០៥.៣០ល្ងាច។នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង១១.៤៨រសៀល លោក[redacted]បានមកតាមច្រកក្រោយតែគាត់មិនបានចូលសណ្ឋាគារទេ។នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ម៉ោង០៣.៥៥នាទីល្ងាច លោក[redacted] បានចូលក្នុងសណ្ឋាគារវិញជាមួយលោក ហេឡេក្ស និងមេធាវីរបស់គាត់ចំនួន០៣នាក់ ព្រមទាំងមានអ្នកកាសែតម្នាក់មកជាមួយផងដែរ(លេខឡានមេធាវីគឺ ២.២៧.៣៤ខម)(លេខឡានអ្នកកាសែតគឺ2A3135pp)។នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨

ពេលដែលលោកហេឡ្លកូ និងលោក [redacted] ចូលដល់សណ្ឋាគារគាត់បានទៅជួបជាមួយ អ្នកគ្រប់គ្រងទូទៅ លោក [redacted] អែល ក្រោយមកគាត់ក៏បានអោយលោក [redacted] អែលចេញពីសណ្ឋាគារវេលាម៉ោងប្រហែល០៧.០០ល្ងាច។នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ម៉ោង១១.៣៤ រសៀល លោក [redacted] លោក [redacted] បានជួបប្រជុំជាមួយមេធាវីរបស់លោក ប៉ូរុំ នៅភោជនីយដ្ឋាន ឡាស្តាល់ខាងក្រៅ និងនៅពេលរសៀលលោក ប៉ាទ្រីក ត្រូវបានក្រុមសមត្ថកិច្ចអោយចេញពីសណ្ឋាគារជាលើកទី២។

-អំណានសេចក្តីជូនដំណឹង ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់ឈ្មោះ ហ្វ្រង់ស្វ័រ កុងដេរ ថាៈប្រធានក្រុមប្រឹក្សាភិបាល និងជាអ្នកគ្រប់គ្រងក្រុមហ៊ុន Victoria Angkor Company Limited (VAK) ដែលវិនិយោគលើសេវាកម្មសណ្ឋាគារ Victoria Angkor Resort Spa តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ៣៧២ (ឈ) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់តុលាការកំពូល។សូមប្រកាសជូនដំណឹងដល់បុគ្គលិក និយោជិតសណ្ឋាគារគ្រប់ថ្នាក់ និងគ្រប់ផ្នែកទាំងអស់ដូចតទៅ: នារយៈពេលកន្លងមកឈ្មោះ [redacted] Le Helloco សញ្ជាតិបារាំង និងគូកន បានធ្វើសកម្មភាពទុច្ចរិតដោយបិទ និងផ្អាកចរន្តគណនីធនាគាររបស់ក្រុមហ៊ុនទាំងបំពានច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរំលោភលើអំណាចសាលដីការដ្ឋប្បវេណីលេខ ៣៧២ (ឈ) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់តុលាការកំពូល យ៉ាងគឃ្លើន ជាហេតុធ្វើប៉ះពាល់ដល់ដំណើរការបើកផ្តល់ឈ្នួលជូនបុគ្គលិក និយោជិតសណ្ឋាគារទាំងមូល ធ្ងន់ធ្ងរបំផុត។ ស្ថិតក្នុងស្ថានភាពក្រុមហ៊ុនកំពុងមានវិធានការច្បាប់ទៅលើជនខិលខូចទុច្ចរិតទាំងនោះ សូមបុគ្គលិក និយោជិតសណ្ឋាគារគ្រប់ជាន់ថ្នាក់ទាំងអស់ រក្សាភាពស្ងៀមស្ងាត់ និងបំពេញការងារតាមតួនាទីរៀងៗខ្លួនជាប្រក្រតី ដោយក្រុមហ៊ុនសន្យាថា នឹងដោះស្រាយបើកផ្តល់ប្រាក់ឈ្នួលជូនស្របតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

**សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី**

-សូមឱ្យតុលាការសម្រេចផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] Le Helloco តាមនីតិវិធីនៃច្បាប់ ពីបទ កំហែងយក និងធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ តាមបញ្ញត្តិមាត្រា ៣៦៣,៣៦៤,៣២៣ នៃក្រមព្រហ្មទណ្ឌ។

-សូមឱ្យតុលាការសម្រេចបង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] Le Helloco សងសំណងការខូចខាតផលប្រយោជន៍របស់ក្រុមហ៊ុន និងជំងឺចិត្ត ព្រមទាំងសេវាផ្លូវច្បាប់ផ្សេងៗ ស្មើនឹងទឹកប្រាក់ចំនួន១០០០.០០០.០០០(មួយពាន់លាន)រៀល។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**

ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ឃើញថាមានភស្តុតាងគ្រប់គ្រាន់ ហេតុនេះ តំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ[illegible]។



-ក្រោយពីបានស្តាប់អំណានពាក្យបណ្តឹងរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់មេធាវីតំណាងអាណត្តិអោយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យភស្តុតាងនិងពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់ហើយ

**សំអាងហេតុ**

១-កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ស្ថិតនៅខេត្តសៀមរាប ពិតជាមានករណី **កំហែងយក និងធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចតុលាការ** ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted]ឡេ ហែលឡូខូ [redacted] LE HELLOCO) ប្រាកដមែន។

២-ចម្លើយជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថាឈ្មោះ [redacted] Albert Pronk ត្រូវបានបញ្ឈប់ពីការងារដោយសារកំហុសធ្ងន់ធ្ងរ ហើយឈ្មោះ [redacted] Guillien ត្រូវចាត់តាំងអោយទទួលការងារជំនួស ប៉ុន្តែត្រូវជនជាប់ចោទបញ្ឈប់ពីការងារដោយបង្ខំជាថ្នូរនឹងទឹកប្រាក់ចំនួន២០០០០(ពីរម៉ឺន)ដុល្លារអាមេរិក ក្នុងគោលបំណងអោយឈ្មោះ [redacted] Albert Pronk កាន់តំណែងជំនួសដោយគ្មានការយល់ព្រមពីដើមបណ្តឹងរដ្ឋប្បវេណី ដែលជាម្ចាស់សណ្ឋាគារឡើយ ម្យ៉ាងទៀតសិទ្ធិនេះជនជាប់ចោទត្រូវបានហាមឃាត់ដោយសេចក្តីសម្រេចរបស់តុលាការ។

៣-ភស្តុតាងដូចសំអាងហេតុក្នុងចំណុច១,២ និងសេចក្តីសន្និដ្ឋានមេធាវីតំណាងអាណត្តិអោយដើមបណ្តឹងរដ្ឋប្បវេណីមានភាពស៊ីសង្វាក់គ្នាជាមួយឯកសារភស្តុតាង ដូចជាពេលសវនាការ,ចៅក្រមស៊ើបសួរ,អយ្យការ ដែលអាចអោយជឿបានថាជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ដូចអង្គហេតុដែលបានបញ្ជូនមកជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ។

៤-សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតបង្ខិតបង្ខំដើម្បីអោយបុគ្គលម្នាក់បោះបង់ការងាររបស់ខ្លួន ហើយដាក់បំពេញបន្ថែមនូវបុគ្គលផ្សេងទៀត ដែលត្រូវបានហាមឃាត់ដោយសេចក្តីសម្រេចរបស់តុលាការ ដែលច្បាប់បញ្ញត្តិថាជាបទល្មើស និងផ្តន្ទាទោស។

៥-អំពើរបស់ជនជាប់ចោទបានប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម។

៦-ជនជាប់ចោទមានកំរិតអាយុអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះអំពើរបស់ខ្លួន។

៧-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទៈឈ្មោះ [redacted] ឡេ ហែលឡូខូ [redacted] LE HELLOCO) ភេទប្រុស អាយុ៤៦ឆ្នាំ ជនជាតិហ្វូឡង់ ពីបទ: **កំហែងយក និងធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចតុលាការ** ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា **៣៦៣,៣៦៤,៥២៣** នៃក្រមព្រហ្មទណ្ឌ។

០៩-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ទាមទារឲ្យតុលាការសម្រេចបង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] Le Helloco សងសំណងការខូចខាតផលប្រយោជន៍របស់ក្រុមហ៊ុន និងជំងឺចិត្ត ព្រមទាំងសេវាផ្លូវច្បាប់ផ្សេងៗស្មើនឹងទឹកប្រាក់ចំនួន១០០០.០០០.០០០(មួយពាន់លាន)រៀល ឃើញថាមានចំនួនច្រើនលើសលប់ គប្បីតុលាការពិចារណា និងសម្រេចតាមភាពសមហេតុផល។

១០-ក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទឈ្មោះ [redacted] ឡេ ហែលឡូខូ ([redacted] LE HELLOCO) បានរត់គេចខ្លួន គប្បីតុលាការ ចេញដីកាបង្គាប់ឲ្យចាប់ខ្លួន និងឃុំតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**<u>ហេតុដូច្នេះសម្រេច</u>**

១-ផ្តន្ទាទោសឈ្មោះ [redacted] ឡេ ហែលឡូខូ [redacted] LE HELLOCO) ភេទប្រុស អាយុ៤៦ឆ្នាំ ជនជាតិហ្វូឡង់ ដាក់ពន្ធនាគារកំណត់៣(បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន៥.០០០.០០០(ប្រាំលាន)រៀល។

ពីបទ: **កំហែងយក និងធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចតុលាការ** ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា **៣៦៣,៣៦៤,៥២៣** នៃក្រមព្រហ្មទណ្ឌ។

២-អោយឈ្មោះ [redacted] ឡេ ហែលឡូខូ [redacted] LE HELLOCO) សងសំណងការខូចខាត និងជម្ងឺចិត្តចំនួន៥០.០០០.០០០(ហាសិបលាន)រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] កុងដេរ [redacted] Gontier) ច្រានចោលការទាមទារលើសពីនេះ។

៣-បង្គាប់អោយឲ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted] ឡេ ហែលឡូខូ [redacted] LE HELLOCO) តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទ,ចំពោះមុខមេធាវីការពារសិទ្ធិ និងតំណាងអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមជំនុំជម្រះ |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៨កើត ខែចេត្រ ឆ្នាំកុរ ទោស័ក ព.ស ២៥៦៣

ធ្វើនៅសៀមរាប ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

| បានឃើញ | |
|---|---|
| ចៅក្រមជំនុំជម្រះ | ក្រឡាបញ្ជី |
| [redacted] | [redacted] |